ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ:..៦៨៥.៦.....សហវ.ប្រក.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាស

## ស្ដីពី

## កម្រិតសោធនភាពសំរាប់ក្រុមហ៊ុនធានារ៉ាប់រងទូទៅ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ស្ដីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្ដីពីការបំពេញបន្ថែម និង ការកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៥៨៤ សហវ ប្រក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្ដីពីការកែសំរួលការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- បានឃើញការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**ប្រការ ១ :** ប្រកាសនេះអនុវត្តចំពោះគ្រប់ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងបន្ត ឬ សាខារបស់ក្រុមហ៊ុនធានារ៉ាប់រងទូទៅ បរទេស និងសាខាក្រុមហ៊ុនធានារ៉ាប់រងបន្តបរទេស ដែលបានទទួលការអនុញ្ញាតអោយធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនគិតដល់ប្រភពនៃកម្មសិទ្ធិ ។

**ប្រការ ២ :** ពាក្យ «សាធនភាព» គឺជាសមត្ថភាពរបស់ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្នុងការរ៉ាប់រងនូវកាតព្វកិច្ច (បំណុល) ទាំងឡាយនៃគ្រប់កិច្ចសន្យាធានារ៉ាប់រង និងគ្រប់ពេលវេលា ។

**ប្រការ ៣ :** មូលដ្ឋានសម្រាប់វាយតម្លៃទ្រព្យសកម្ម និងទ្រព្យអកម្ម(បំណុល)ត្រូវអនុវត្តតាមប្រកាសស្តីពីគោលការណ៍ណែនាំផ្នែកគណនេយ្យ សម្រាប់ក្រុមហ៊ុនធានារ៉ាប់រងទូទៅនៅកម្ពុជា ។

**ប្រការ ៤ :** ដោយយោងតាមមាត្រា ៥៦ នៃអនុក្រឹត្យស្តីពីការធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងទូទៅនីមួយៗ ដែលបានទទួលអាជ្ញាប័ណ្ណ ត្រូវរក្សាទុកនូវប្រាក់កំរិតសាធនភាពដូចកំណត់ខាងក្រោម :

១- ក្នុងឆ្នាំដំណើរការដំបូង ត្រូវមាន ៥០ ភាគរយ នៃដើមទុនចុះបញ្ជីតាមច្បាប់ ។

២- នៅពេលចំណូលបុព្វលាភរ៉ាប់រងសរុបដកចេញបុព្វលាភរ៉ាប់រងបន្តសរុបប្រចាំឆ្នាំមុន នៅស្មើ ឬទាបជាង ៦៦.៥០០ លានរៀល ត្រូវមាន ១៣.៣០០ លានរៀល ។

៣- នៅពេលចំណូលបុព្វលាភរ៉ាប់រងសរុប ដកចេញនូវបុព្វលាភរ៉ាប់រងបន្តសរុបប្រចាំឆ្នាំមុនមានចំនួនពី ៦៦.៥០០ លានរៀល ដល់ ៣៣២. ៥០០ លានរៀល ត្រូវមាន ម្ភៃ (២០) ភាគរយ នៃចំណូលបុព្វលាភសរុបឆ្នាំមុន ។

៤- នៅពេលបុព្វលាភរ៉ាប់រងសរុបដកចេញនូវបុព្វលាភរ៉ាប់រងបន្តសរុបប្រចាំឆ្នាំមុនមានចំនួនលើសពី ៣៣២.៥០០ លានរៀល ត្រូវមាន : ៦៦.៥០០ លានរៀល បូកនឹង ១០ ភាគរយ នៃចំណែកបុព្វលាភដែលលើសពី ៣៣២.៥០០ លានរៀល ។

**ប្រការ ៥ :** ដោយអនុលោមតាមមាត្រា ៥៣ នៃអនុក្រឹត្យស្តីពីការធានារ៉ាប់រង ចំនួនទឹកប្រាក់កម្រិតសាធនភាព ៥០ភាគរយ នៃដើមទុនចុះបញ្ជី ត្រូវរក្សាទុកក្នុងធនាគារពាណិជ្ជមួយដែលមានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៦ :**

១- ដោយអនុលោមតាមមាត្រា ៦៧ នៃអនុក្រឹត្យស្តីពីការធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ត្រូវធ្វើការធានារ៉ាប់រងបន្ត ទៅក្រុមហ៊ុនធានារ៉ាប់រងបន្តរបស់រដ្ឋចំនួនម្ភៃ (២០)ភាគរយ យ៉ាងតិចនៃសេវាកម្មធានារ៉ាប់រង ។

២- ដើម្បីធានាបាននូវសុវត្ថិភាពទីផ្សារ ក្រុមហ៊ុនធានារ៉ាប់រងនៅកម្ពុជា ត្រូវធ្វើការធានារ៉ាប់រងបន្ត

ជាមួយក្រុមហ៊ុនធានារ៉ាប់រងបរទេសទាំងឡាយណា ដែលមានចំណាត់ថ្នាក់បច្ចុប្បន្នអប្បបរមា BBB របស់ក្រុមហ៊ុន Standard & Poor's (S&P) ឬចំណាត់ថ្នាក់សមមូលរបស់ភ្នាក់ងារចាត់ថ្នាក់ ដែលទទួលស្គាល់ជាអន្តរជាតិ ។

**ប្រការ ៧ :** ក្រុមហ៊ុនដែលទទួលអាជ្ញាប័ណ្ណ មិនត្រូវអនុញ្ញាតឱ្យបែងចែកភាគលាភលើប្រាក់ចំណេញទៅអោយភាគទុនិករបស់ខ្លួននោះទេ លើកលែងតែក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុពិនិត្យឃើញថា ក្រុមហ៊ុននោះបាននិងកំពុងបំពេញកម្រិតសាធនភាពរួចហើយ ។ ក្នុងករណីនេះ ការបែងចែកភាគលាភអាចធ្វើឡើងបានតែក្នុងករណីដែលមានការឯកភាពជាលាយលក្ខណ៍អក្សរ ពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។

**ប្រការ ៨ :** គ្រប់ក្រុមហ៊ុនដែលទទួលអាជ្ញាប័ណ្ណ ត្រូវផ្ញើជូនក្រសួង នូវរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍បញ្ជាក់អំពីកម្រិតសាធនភាព តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ ៩ :** ក្រុមហ៊ុនណាដែលប្រព្រឹត្តផ្ទុយនឹងប្រការណាមួយនៃប្រកាសនេះ នឹងត្រូវទទួលការផាកពិន័យជាប្រាក់ចំនួន ១០ លានរៀល ក្នុងរយៈពេល ពីរ (២)សប្តាហ៍ បង់ចូលរតនាគារជាតិ តាមដីការអមរបស់នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

**ប្រការ ១០ :** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីការកំណត់នៅក្នុងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១១ :** ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**ចំលងជូន :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រាជកិច្ច "ដើម្បីចុះផ្សាយ"
- ឯកសារ-កាលប្បវត្តិ